# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សភាពាណិជ្ជកម្ម រាជធានីភ្នំពេញ
ចូល
លេខៈ 197
ថ្ងៃទី 28-3-19 ម៉ោង 2:00PM
បញ្ជូន [illegible]

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការលើកទឹកចិត្តផ្នែកពន្ធ សម្រាប់សហគ្រាសធុនតូចនិងមធ្យម

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាព
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងលើកកម្ពស់ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ដើម្បីបង្កើតការងារ បង្កើនសមត្ថភាព និងលទ្ធភាពប្រកួតប្រជែងរបស់ផលិតកម្មក្នុងស្រុក។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់លក្ខខណ្ឌ សម្រាប់ផ្តល់ការលើកទឹកចិត្តផ្នែកពន្ធចំពោះសហគ្រាសធុនតូចនិងមធ្យម។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះតែសហគ្រាសធុនតូចនិងមធ្យម ដែលស្ថិតក្នុងវិស័យអាទិភាព ដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ។

## ជំពូកទី ២
## និយមន័យ និងវិស័យអាទិភាព

**មាត្រា ៤.-**

ក្នុងន័យនៃអនុក្រឹត្យនេះ វាក្យស័ព្ទ÷

១- ពាក្យ“សហគ្រាសធុនតូច” និង“សហគ្រាសធុនមធ្យម” សំដៅដល់សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម ដូចមានចែងក្នុងអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាព។

២- ពាក្យ “សម្ភារបរិក្ខារផលិតកម្ម” សំដៅដល់គ្រឿងម៉ាស៊ីន ឧបករណ៍ដែលបានប្រើប្រាស់ជាមូលដ្ឋានក្នុងការបំប្លែងធាតុចូលផលិតកម្ម ហើយដែលវត្ថុទាំងនោះ មិនអាចបំប្លែងបានដោយខ្លួនឯង ឬមិនត្រូវបានប្រើប្រាស់អស់ក្នុងរយៈពេល ២ (ពីរ) ឆ្នាំ បន្ទាប់ពីបាននាំចូល។

៣- ពាក្យ “សម្ភារសាងសង់” សំដៅដល់ សម្ភារសំណង់ រួមទាំងឧបករណ៍ បរិក្ខារ ដែលបានបំប្លែង ឬបានប្រើប្រាស់ទាំងស្រុងនៅក្នុងការសាងសង់សំណង់បម្រើឱ្យផលិតកម្ម។

៤- ពាក្យ “ធាតុចូលផលិតកម្ម” សំដៅដល់ទំនិញ រួមបញ្ចូលទាំងវត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច និងសម្ភារបន្ទាប់បន្សំបម្រើឱ្យផលិតកម្ម ដែលត្រូវបានបំប្លែង ឬត្រូវបានប្រើប្រាស់យ៉ាងពេញលេញនៅក្នុងកិច្ចដំណើរការផលិតកម្ម មិនឱ្យហួសរយៈពេល ២ (ពីរ) ឆ្នាំ បន្ទាប់ពីបាននាំចូល។

៥- សម្ភារបរិក្ខារផលិតកម្ម សម្ភារសាងសង់ និងធាតុចូលផលិតកម្ម មិនគិតបញ្ចូលនូវ យានយន្ត គ្រឿងបន្លាស់យានយន្ត ផលិតផលគេលសិលា និងសម្ភារបរិក្ខារនិងគ្រឿងសង្ហារិមសម្រាប់ប្រើប្រាស់ក្នុងការិយាល័យ។

៦- ពាក្យ "សហគ្រាសផលិតនិងផ្គត់ផ្គង់ទឹកស្អាត" សំដៅដល់សហគ្រាសដែលធ្វើការផលិតនិងផ្គត់ផ្គង់ទឹកស្អាត សម្រាប់ការប្រើប្រាស់ក្នុងជីវភាពរស់នៅ ឬការប្រកបអាជីវកម្ម ដោយមិនរាប់បញ្ចូលសហគ្រាសផលិតទឹកសម្រាប់ទទួលទានគ្រប់ប្រភេទ។

៧- ពាក្យ "សហគ្រាសបម្រើឱ្យការនាំចេញ" សំដៅដល់សហគ្រាសធុនតូចនិងមធ្យម ដែលបានលក់ ឬផ្ទេរសមាមាត្រណាមួយនៃផលិតផលរបស់ខ្លួន ទៅឱ្យអ្នកទិញ ឬអ្នកទទួលនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

៨- ពាក្យ "សហគ្រាសជាប្រភេទឧស្សាហកម្មគាំទ្រ" សំដៅដល់សហគ្រាសធុនតូចនិងមធ្យម ដែលផលិតផលរបស់ខ្លួន ត្រូវបានផ្គត់ផ្គង់ដល់សហគ្រាសនាំចេញ ជំនួសវត្ថុធាតុដើម ឬសម្ភារបន្ទាប់បន្សំដែលនាំចូល។

៩- ពាក្យ "សហគ្រាសបម្រើតម្រូវការក្នុងស្រុក" សំដៅដល់សហគ្រាសធុនតូចនិងមធ្យម ដែលមិនបម្រើឱ្យការនាំចេញ។

១០- ពាក្យ "ពន្ធគយ" សំដៅដល់ពន្ធនាំចូលដែលត្រូវយកលើទំនិញស្របតាមបញ្ញត្តិនៃច្បាប់ស្ដីពីគយ ដោយមិនរាប់បញ្ចូលនូវអាករពិសេស អាករលើតម្លៃបន្ថែម កម្រៃ ឬបន្ទុកផ្សេងទៀត។

**មាត្រា ៥.-**

សម្រាប់គោលដៅនៃអនុក្រឹត្យនេះ វិស័យអាទិភាពត្រូវបានកំណត់ដូចខាងក្រោម÷

១- សហគ្រាសផលិតនិងផ្គត់ផ្គង់ទឹកស្អាត

២- ផលិតកម្មកសិកម្ម ឬកសិ-ឧស្សាហកម្ម

៣- ផលិតកម្មផលិត និងកែច្នៃម្ហូបអាហារ

៤- កម្មន្តសាលផលិតទំនិញបម្រើឱ្យការនាំចេញ

៥- កម្មន្តសាលផលិតទំនិញប្រើប្រាស់ក្នុងស្រុក, កែច្នៃកាកសំណល់ និងផលិតទំនិញសម្រាប់វិស័យទេសចរណ៍

៦- កម្មន្តសាលផលិតនូវផលិតផលសម្រេច ឬផលិតផលពាក់កណ្ដាលសម្រេច ឬផ្នែក ឬគ្រឿងបង្គុំ ដើម្បីផ្គត់ផ្គង់ឱ្យកម្មន្តសាលដទៃទៀត

៧- ការស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន ដែលមានលក្ខណៈនវានុវត្តន៍

៨- អ្នកអភិវឌ្ឍន៍តំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម

វិស័យអាទិភាពនេះ មិនរួមបញ្ចូលវិស័យដែលប៉ះពាល់ដល់សន្តិសុខសង្គម សុខភាព និងបរិស្ថាន។

## ជំពូកទី ៣
## ការលើកទឹកចិត្តផ្នែកគយ

**មាត្រា ៦.-**

សហគ្រាសធុនតូចនិងមធ្យមដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវទទួលបានការលើកទឹកចិត្តលើពន្ធគយតាមលក្ខខណ្ឌដូចខាងក្រោម÷

១- សហគ្រាសផលិតនិងផ្គត់ផ្គង់ទីកស្អាត÷ ត្រូវបានទទួលបានប្រព្រឹត្តកម្មលើកលែងពន្ធគយដូចនឹងសហគ្រាសបម្រើឱ្យការនាំចេញ។

២- សហគ្រាសបម្រើឱ្យការនាំចេញ÷ ត្រូវបានលើកលែងពន្ធគយ លើសម្ភារបរិក្ខារផលិតកម្ម សម្ភារសាងសង់ និងធាតុចូលផលិតកម្ម។ ក្នុងករណីធាតុចូលផលិតកម្មរបស់សហគ្រាសប្រភេទនេះ ត្រូវបានកែច្នៃហើយមិនបាននាំចេញ ត្រូវបំពេញកាតព្វកិច្ចពន្ធឡើងវិញលើធាតុចូលផលិតកម្ម នាពេលនាំចូល ក្រោយពីការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ។

៣- សហគ្រាសជាប្រភេទឧស្សាហកម្មគាំទ្រ÷ ត្រូវបានលើកលែងពន្ធគយ លើសម្ភារបរិក្ខារផលិតកម្ម សម្ភារសាងសង់ និងធាតុចូលផលិតកម្ម សម្រាប់ផលិតផ្គត់ផ្គង់ដល់សហគ្រាសបម្រើឱ្យការនាំចេញ។ ក្នុងករណីធាតុចូលផលិតកម្មរបស់សហគ្រាសប្រភេទនេះត្រូវបានកែច្នៃ ហើយមិនបានផ្គត់ផ្គង់ដល់សហគ្រាសបម្រើឱ្យការនាំចេញ ឬមិនបាននាំចេញដោយផ្ទាល់ ត្រូវបំពេញកាតព្វកិច្ចពន្ធឡើងវិញលើធាតុចូលផលិតកម្មនាពេលនាំចូល ក្រោយពីការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ។

៤- សហគ្រាសបម្រើតម្រូវការក្នុងស្រុក÷ ត្រូវបានលើកលែងពន្ធគយ តែលើសម្ភារបរិក្ខារផលិតកម្ម និងសម្ភារសាងសង់។ ក្នុងករណីសហគ្រាសប្រភេទនេះ មានលទ្ធភាពនាំចេញនូវផ្នែកណាមួយនៃផលិតផលដែលផលិតដោយផ្ទាល់ បរិមាណធាតុចូលផលិតកម្មដែលបានបង់ពន្ធគយរួចយកទៅបម្រើការនាំចេញដោយផ្ទាល់ ឬដោយប្រយោលនោះ ត្រូវទទួលបានការលើកលែងពន្ធគយ ក្រោយពីការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ។

៥- ការស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន ÷ ត្រូវបានលើកលែងពន្ធគយ លើសម្ភារបរិក្ខារសម្រាប់ដំឡើង និងប្រើប្រាស់ក្នុងការស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានដែលមានលក្ខណៈនវានុវត្តន៍។

៦- អ្នកអភិវឌ្ឍន៍តំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម÷ ត្រូវបានទទួលបានប្រព្រឹត្តកម្មលើកលែងពន្ធគយដូចនឹងសហគ្រាសបម្រើតម្រូវការក្នុងស្រុក។

ក្នុងករណីរកឃើញថាមានការប្រើប្រាស់ខុសគោលដៅ មុខទំនិញដែលទទួលបានការលើកទឹកចិត្តខាងលើ ត្រូវជាកម្មវត្ថុនៃការបំពេញកាតព្វកិច្ចពន្ធឡើងវិញ និងការពិន័យស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា ៧.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់នូវបញ្ញត្តិពាក់ព័ន្ធនឹងលក្ខខណ្ឌ, ទម្រង់, នីតិវិធី និងយន្តការ នៃការផ្តល់ និងការតាមដានត្រួតពិនិត្យការលើកទឹកចិត្តដល់សហគ្រាសធុនតូចនិងមធ្យម ស្របតាមបទបញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា ៨.-**

សហគ្រាសធុនតូចនិងមធ្យម ដែលរំលោភបំពានលើច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ត្រូវប្រឈមនឹងការដកហូតការលើកទឹកចិត្តដូចមានចែងក្នុងបញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៥ រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ មីនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ